**រាជរដ្ឋាភិបាល**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# គោលនយោបាយ

# ស្ដីពី

# សុវត្ថិភាពបរិស្ថាន និងសង្គម

# សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**ឆ្នាំ២០១៩**

# អារម្ភកថា

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាក្របខណ្ឌគតិយុត្តដ៏ចម្បង សម្រាប់កិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឡើងនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការលើកកម្ពស់អភិបាលកិច្ច ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន គណនេយ្យភាព និងតម្លាភាព សំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌សង្គម។

គោលនយោបាយស្តីពី " សុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ" គឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ មានគោលដៅពង្រឹងការចូលរួម ការទទួលខុសត្រូវ តម្លាភាព និងប្រសិទ្ធភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើកិច្ចការពារបរិស្ថាន និងសង្គម ស្របតាមកម្រិតបទដ្ឋានជាតិ និងអន្តរជាតិនៅក្នុងការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ។ គោលនយោបាយនេះ តម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ខ្ពស់លើផលប៉ះពាល់ និងហានិភ័យចំពោះ បរិស្ថាន និងសង្គម ដែលអាចកើតមានឡើងដោយសារការអនុវត្តគម្រោង ដោយផ្តោតការយកចិត្តទុកដាក់លើសមធម៌យេនឌ័រ ក្រុមជនងាយរងគ្រោះ ជនជាតិដើមភាគតិច និងបេតិកភណ្ឌវប្បធម៌។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ គ.ជ.អ.ប. បានកំណត់នូវយុទ្ធសាស្ត្រចំនួនប្រាំបី សម្រាប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានា យកទៅអនុវត្ត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានដូចជា ការវិភាគ និងគ្រប់គ្រងផលប៉ះ ពាល់បរិស្ថាននិងហានិភ័យសង្គម ការលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាននានា និងការគ្រប់គ្រងបរិស្ថាន ការលើកកម្ពស់សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍ ការលើកកម្ពស់ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។ល។

គ.ជ.អ.ប. មានសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងភាគីពាក់ព័ន្ធនានាចូលរួមយ៉ាងសកម្មក្នុងការផ្សព្វផ្សាយ ការគាំទ្រ និងការអនុវត្តនូវគោលនយោបាយ ស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទទួលបានជោគជ័យ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់៕

ថ្ងៃ.....................ខែ............... ឆ្នាំកុរ ឯកស័ក ព.ស.............

រាជធានីភ្នំពេញ,ថ្ងៃទី...........ខែ.............ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**សម្តេចក្រឡាហោម ស ខេង**

## មាតិកា


I. សេចក្តីផ្តើម......1

II. សនិទានភាព និងក្របខណ្ឌគតិយុត្ត ......1

III. ចក្ខុវិស័យ......2

IV. គោលបំណង គោលដៅ និងវិសាលភាព......2

១. គោលបំណង ......2

២. គោលដៅ......2

៣. វិសាលភាព ......3

VI. យុទ្ធសាស្ត្រ......3

យុទ្ធសាស្ត្រទី១ ៖ ការវិភាគ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងហានិភ័យសង្គម ......3

យុទ្ធសាស្ត្រទី២ ៖ ពលកម្ម និងលក្ខខណ្ឌការងារ ......4

យុទ្ធសាស្ត្រទី៣ ៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន ......5

យុទ្ធសាស្ត្រទី៤ ៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍......6

យុទ្ធសាស្ត្រទី៥ ៖ លទ្ធកម្មដីធ្លី និងតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត......7

យុទ្ធសាស្ត្រទី៦ ៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិត ប្រកបដោយចីរភាព ......7

យុទ្ធសាស្ត្រទី៧ ៖ ជនជាតិដើមភាគតិច......9

យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌ ......9

VIII. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ......10

១. យន្តការ ......10

២. ការដឹកនាំ និងសម្របសម្រួល......11

៣. ការគាំទ្រហិរញ្ញវត្ថុ......11

VII. ផែនការសកម្មភាព......11

VIII. ភស្តុតាង និងយន្តការដោះស្រាយពាក្យបណ្តឹង ......12

IX. សេចក្តីសន្និដ្ឋាន......13

សន្ទានុក្រម......14

ឧបសម្ព័ន្ធ......17

## I. សេចក្តីផ្តើម

កិច្ចការពារបរិស្ថាន និងសង្គម គឺជាប្រធានបទមួយដ៏សំខាន់នៅក្នុងដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សំដៅធានាដល់ការវិនិយោគសាធារណៈ ដែលមិនបង្កនូវផលប៉ះពាល់ជាអវិជ្ជមាន ឬការគំរាមកំហែងទៅលើនិរន្តរភាពនៃលំនឹងបរិស្ថាន ប្រព័ន្ធអេកូឡូស៊ី សង្គម វប្បធម៌ ប្រពៃណី ជនជាតិដើមភាគតិច និងបញ្ចៀសឱ្យបាននូវផលប៉ះពាល់ជាអវិជ្ជមានទៅលើសុខភាព សេដ្ឋកិច្ច យេនឌ័រ និងការរំលោភបំពានផ្សេងៗដែលបណ្តាលពីកិច្ចអភិវឌ្ឍន៍ទាំងនោះ។

ក្នុងគោលបំណងការពារឱ្យបាននូវផលប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន និងសង្គម គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) បានដាក់ចេញនូវគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានយុទ្ធសាស្ត្រចំនួនប្រាំបីចំណុចពោលគឺ ទី១. ការវិភាគ និងការគ្រប់គ្រងផលប៉ះពាល់ជាអវិជ្ជមានលើបរិស្ថាន និងហានិភ័យសង្គម ទី២. ពលកម្ម និងលក្ខខណ្ឌការងារ ទី៣. ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន ទី៤. សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍ ទី៥. លទ្ធកម្មដីធ្លី និងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត ទី៦. ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព ទី៧. ជនជាតិដើមភាគតិច និង ទី៨. បេតិកភណ្ឌវប្បធម៌។

## II. សនិទានភាព និងគ្រួបខណ្ឌគតិយុត្ត

នៅឆ្នាំ២០០៩ ដោយមានការគាំទ្របច្ចេកទេសពីដៃគូអភិវឌ្ឍ គ.ជ.អ.ប.បានសហការជាមួយអ្នកពាក់ព័ន្ធនានារៀបចំបង្កើតយន្តការកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងស្តីពី "ការវិនិយោគនៅរដ្ឋបាលថ្នាក់ក្រោមជាតិ(RILGP)"។ យន្តការនេះបានបន្តអនុវត្ត និងអភិវឌ្ឍជាបន្តបន្ទាប់សម្រាប់គម្រោងមូលនិធិឃុំ សង្កាត់ស្របតាមបរិបទនៃកំណែទម្រង់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

កន្លងមក យន្តការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចបានអនុវត្តនៅក្នុងគម្រោងមូលនិធិឃុំ សង្កាត់តែប៉ុណ្ណោះ បច្ចុប្បន្នយន្តការនេះបានពង្រីកវិសាលភាពគ្របដណ្តប់លើការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ខណ្ឌ និងគម្រោងរាជធានី ខេត្ត ដូចដែលមានចែងនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោង។

ទោះយ៉ាងណា កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដែលមានស្រាប់នោះនៅមិនទាន់ឆ្លើយតបទៅនឹងបរិបទថ្មីនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងសង្គមនាពេលបច្ចុប្បន្ននៅឡើយ។ អាស្រ័យហេតុនេះ គ.ជ.អ.ប. បានរៀបចំឱ្យមានគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម ដែលកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗនានាសម្រាប់ពង្រឹងប្រព័ន្ធគ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកិច្ចការពារសុវត្ថិភាពប្រកបដោយភាពប្រាកដប្រជា ការទទួលខុសត្រូវខ្ពស់ តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងការលើកកម្ពស់សមធម៌យេនឌ័រស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ និងអាចអនុវត្តទៅបាននៅថ្នាក់ក្រោមជាតិ។

ការរៀបចំ និងអនុវត្តគោលនយោបាយនេះ គឺជាយន្តការមួយដ៏សំខាន់ដែលបង្កឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយនេះប្រកបដោយការទទួលខុសត្រូវ ប្រសិទ្ធភាព និងប្រសិទ្ធផល។

គោលនយោបាយស្ដីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានរៀបចំស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ជាតិ និងអន្តរជាតិ។ ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិពាក់ព័ន្ធនានា រួមមាននៅក្នុងឧបសម្ព័ន្ធទី១ នៃគោលនយោបាយនេះ។

ក្នុងករណីដែលមានការគាំទ្រហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គមអាចត្រូវបានរៀបចំដោយដៃគូអភិវឌ្ឍន៍។ ក្នុងន័យនេះយុទ្ធសាស្ត្រទាំងប្រាំបីនៃគោលនយោបាយស្ដីពីសុវត្ថិភាពបរិស្ថាន និងសង្គម ក៏ត្រូវបានតម្រឹមគ្នានឹងបទដ្ឋានទាំងប្រាំបីនៃការអនុវត្តសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលអនុវត្តដោយស្ថាប័នអន្តរជាតិដូចជា ធនាគារពិភពលោក និងមូលនិធិអាកាសធាតុបៃតងជាដើម។

ក្នុងករណីផ្សេងទៀតការអនុវត្តគោលនយោបាយ ស្ដីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក៏នឹងត្រូវអនុលោមតាមតម្រូវការអភិវឌ្ឍន៍ដៃគូអន្តរជាតិផងដែរ។

## III. ចក្ខុវិស័យ

រាជរដ្ឋាភិបាលកម្ពុជា មានចក្ខុវិស័យលើកកម្ពស់សុខុមាលភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យមានភាពប្រសើរឡើងស្របទៅនឹងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយធានាមិនឱ្យមានផលប៉ះពាល់ជាអវិជ្ជមាន ឬហានិភ័យចំពោះបរិស្ថាន ធនធានធម្មជាតិ សង្គម ប្រពៃណី ទំនៀមទម្លាប់ សិទ្ធិនៃការរស់នៅ និងសេចក្ដីប្រាថ្នារបស់ប្រជាពលរដ្ឋ។

## IV. គោលបំណង គោលដៅ និងវិសាលភាព

### ១. គោលបំណង

គោលនយោបាយនេះ រៀបចំឡើងក្នុងគោលបំណងរក្សាឱ្យបាននូវនិរន្តរភាពប្រព័ន្ធអេកូឡូស៊ី លំនឹងបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ជនជាតិដើមភាគតិច សមភាពយេនឌ័រ សុវត្ថិភាព និងសុខុមាលភាពសង្គមនៅមូលដ្ឋាន។

### ២. គោលដៅ

គោលនយោបាយនេះ មានគោលដៅបញ្ចៀសឱ្យបាននូវរាល់ផលប៉ះពាល់ជាអវិជ្ជមានទាំងឡាយដែលអាចកើតមានឡើងចំពោះបរិស្ថាន និងសង្គម ដែលបណ្ដាលមកពីគម្រោងអភិវឌ្ឍនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

### ៣. វិសាលភាព

គោលនយោបាយស្ដីពីសុវត្ថិភាពបរិស្ថាន និងសង្គមមានវិសាលភាពគ្របដណ្ដប់លើការអនុវត្តគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមានរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ព្រមទាំងគម្រោងទាំងឡាយណាដែលស្ថិតក្រោមកិច្ចកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## VI. យុទ្ធសាស្ត្រ

ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅនៃគោលនយោបាយស្ដីពីសុវត្ថិភាពបរិស្ថាន និងសង្គមឱ្យទទួលជោគជ័យ គ.ជ.អ.ប. បានកំណត់នូវយុទ្ធសាស្ត្រចំនួនប្រាំបីដូចខាងក្រោម៖

យុទ្ធសាស្ត្រទី១៖ ការវិភាគ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងហានិភ័យសង្គម
យុទ្ធសាស្ត្រទី២៖ ពលកម្ម និងលក្ខខណ្ឌការងារ
យុទ្ធសាស្ត្រទី៣៖ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន
យុទ្ធសាស្ត្រទី៤៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍
យុទ្ធសាស្ត្រទី៥៖ លទ្ធកម្មដីធ្លី និងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត
យុទ្ធសាស្ត្រទី៦៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព
យុទ្ធសាស្ត្រទី៧៖ ជនជាតិដើមភាគតិច
យុទ្ធសាស្ត្រទី៨៖ បេតិកភណ្ឌវប្បធម៌

### យុទ្ធសាស្ត្រទី១ ៖ ការវិភាគ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងហានិភ័យសង្គម

យុទ្ធសាស្ត្រនេះគឺជាគោលការណ៍រួមសម្រាប់ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការវិភាគ និងគ្រប់គ្រងផលប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតមានឡើងដោយផ្ទាល់ ឬដោយប្រយោលនៅដំណាក់កាលដំបូងនៃការរៀបចំតាក់តែងគម្រោង។ ផលប៉ះពាល់ និងហានិភ័យទាំងនោះអាចប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ដែលបង្កឱ្យមានការខូចខាត និងមានការបំពុលនានាចំពោះបរិស្ថាន ធនធានធម្មជាតិ ជីវចម្រុះ ដីធ្លី ទ្រព្យសម្បត្តិវប្បធម៌ ប្រពៃណី ទីសក្ការបូជារបស់ជនជាតិដើមភាគតិច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ អាស្រ័យហេតុនេះ ដើម្បីបញ្ចៀសហានិភ័យ និងផលប៉ះពាល់ជាអវិជ្ជមានទាំងនេះ សៀវភៅណែនាំស្ដីពីការអនុវត្តគម្រោងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ត្រូវកំណត់អំពីគោលការណ៍ជាអាទិភាពនានាដែលត្រូវអនុវត្តក្នុងដំណាក់កាលរៀបចំគម្រោងដែលរួមមានដូចខាងក្រោម៖

- ការវិភាគ និងការវាយតម្លៃលើផលប៉ះពាល់ និងហានិភ័យនានាចំពោះបរិស្ថាន និងសង្គម
- ការសិក្សាអំពីប្រសិទ្ធផលធនធាន និងការបង្ការ និងការគ្រប់គ្រងការបំពុល
- ការសិក្សាអំពីលក្ខខណ្ឌពលកម្ម និងលក្ខខណ្ឌការងារ
- ការវិភាគ និងការវាយតម្លៃលើផលប៉ះពាល់សុខភាព និងសុវត្ថិភាពសហគមន៍
- ការវិភាគ និងការវាយតម្លៃលើផលប៉ះពាល់លទ្ធកម្មដីធ្លី ការប្រើប្រាស់ដីធ្លី និងការផ្លាស់ទីលំនៅដោយមិនស្ម័គ្រចិត្ត
- ការសិក្សាអំពីផលប៉ះពាល់លើកិច្ចអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិត

- ការវិភាគ និងការវាយតម្លៃផលប៉ះពាល់ទៅលើជនជាតិដើមភាគតិច
- ការសិក្សាអំពីផលប៉ះពាល់លើបេតិកភណ្ឌវប្បធម៌
- ការស្រង់ និងការប្រមូលផ្តុំទិន្នន័យផលប៉ះពាល់ និងហានិភ័យចំពោះបរិស្ថាន និងសង្គម ដើម្បីរៀបចំផែនការបង្ការ ឬបញ្ជៀសផលប៉ះពាល់
- ការសិក្សាពីជម្រើសនានា ដើម្បីបង្ការ បញ្ជៀស ឬកាត់បន្ថយឱ្យនៅកម្រិតទាបបំផុតនូវផលប៉ះពាល់ជាអវិជ្ជមាន និងហានិភ័យចំពោះបរិស្ថាន និងសង្គម
- ការវាយតម្លៃ ការកាត់បន្ថយ និងការធ្វើឱ្យប្រសើរឡើងនូវផលប៉ះពាល់ជាអវិជ្ជមានចម្បងៗដែលបានសិក្សារួច
- ការរៀបចំកិច្ចពិភាក្សា ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធប្រកបដោយបរិយាប័ន្ន ដោយធានាឱ្យមានការចូលរួមពីស្ត្រី បុរស ជនពិការ ចាស់ជរា ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងៗទៀត
- ការតាមដានត្រួតពិនិត្យ ការផ្តល់ព័ត៌មានត្រលប់ និងការរៀបចំរបាយការណ៍។

## យុទ្ធសាស្ត្រទី២ ៖ ពលកម្ម និងលក្ខខណ្ឌការងារ

ដើម្បីបង្កើតឱកាសការងារ បង្កើនប្រាក់ចំណូលប្រកបដោយបរិយាប័ន្ន និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅមូលដ្ឋាន រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រប់គ្រង និងទទួលខុសត្រូវលើការប្រើប្រាស់កម្មករ និងនិយោជិត និងការអនុវត្តលក្ខខណ្ឌការងាររបស់អ្នកទទួលការ និងអ្នកផ្តល់សេវាស្របតាមច្បាប់ស្តីពីការងារ។ សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ត្រូវយកចិត្តទុកដាក់កំណត់អំពីលក្ខខណ្ឌនៃការប្រើប្រាស់ពលកម្ម និងលក្ខខណ្ឌការងាររវាងអ្នកទទួលការ និងអ្នកផ្តល់សេវាជាមួយកម្មករ និងនិយោជិតនៅក្នុងការអនុវត្តគម្រោងនានានៅថ្នាក់ក្រោមជាតិ ដើម្បីរក្សាបាននូវសុវត្ថិភាពការងារ និងសុខុមាលភាពរបស់កម្មករ និងនិយោជិត។ គោលការណ៍ណែនាំក្នុងការអនុវត្តយុទ្ធសាស្ត្រនេះត្រូវផ្តោតលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ផ្តល់នូវព័ត៌មានអំពីសិទ្ធិដល់កម្មករ និងនិយោជិត រួមមានដូចជា ពេលវេលាអនុវត្តការងារ ការទូទាត់ ការផ្តល់សំណង និងអត្ថប្រយោជន៍ផ្សេងៗដែលកម្មករ និងនិយោជិតទទួលបាន
- ផ្តល់នូវសុវត្ថិភាព និងសុខុមាលភាពចំពោះកម្មករ និយោជិតក្នុងពេលបំពេញការងារ និងលក្ខខណ្ឌការងារ ដោយរួមបញ្ចូលទាំងការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ការងារ
- ផ្អែកទៅលើគោលការណ៍ស្មើភាពគ្នា និងសមធម៌យេនឌ័រ ដោយមិនមានការរើសអើងក្នុងការផ្តល់សំណង ការផ្តល់ឱកាសការងារ ការគ្រប់គ្រង និងការបណ្តេញចេញពីការងារ
- គ្មានការរឹតត្បិតលើសិទ្ធិសេរីភាពកម្មករក្នុងការចូលរួមបង្កើតសហជីព
- រៀបចំយន្តការទទួលពាក្យបណ្តឹង និងឆ្លើយតបសម្រាប់កម្មករ
- ទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារស្របទៅតាមច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីការទប់ស្កាត់ពលកម្មកុមារ។ ជៀសវាងឱ្យបានការប្រើប្រាស់ពលកម្មដែលពាក់ព័ន្ធនឹងគម្រោងដែលអាចបង្កឱ្យមានគ្រោះថ្នាក់ ឬរំខានដល់ការអប់រំរបស់កុមារ ឬអាចបង្កការគ្រោះថ្នាក់ដល់សុខភាព ឬការអភិវឌ្ឍផ្នែកកាយសម្បទា ផ្លូវចិត្ត ស្មារតី សីលធម៌ ឬសង្គមរបស់កុមារ
- គ្មានការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ ឬការជួញដូរមនុស្ស

- ធានារក្សានូវសិទ្ធិ(លក្ខខណ្ឌការងារ)របស់កម្មករ និយោជិត ដែលត្រូវបានផ្តល់កិច្ចសន្យាដោយអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មបន្ត
- ត្រួតពិនិត្យជាប្រចាំទៅលើការអនុវត្តការងារដោយគិតពីសុវត្ថិភាពជាចម្បង ដើម្បីកាត់បន្ថយហានិភ័យទៅលើការប្រើប្រាស់កម្លាំងពលកម្ម។

**យុទ្ធសាស្ត្រទី៣ ÷ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន**

ការប្រើប្រាស់ធនធាន និងការគ្រប់គ្រងការបំពុលនៅមូលដ្ឋានត្រូវធានាដល់ការប្រើប្រាស់នូវធនធានដែលមានស្រាប់ក្នុងសហគមន៍ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល សំដៅរួមចំណែកក្នុងការអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានប្រកបដោយចីរភាព។ ធនធានទាំងនោះរួមមានដូចជា ប្រភពទឹក គ្រួស ថ្ម ដី ជាដើម ដែលត្រូវគ្រប់គ្រង ប្រើប្រាស់ និងរក្សាឲ្យបាននូវនិរន្តរភាពនៃធនធាន និងមិនបង្កផលប៉ះពាល់ដល់សហគមន៍។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានាដល់ការគ្រប់គ្រងនូវការបំពុលបរិស្ថាន ដែលបណ្តាលមកពីសកម្មភាពនៃការអភិវឌ្ឍក្នុងរយៈពេលខ្លី និងរយៈពេលវែង ដែលអាចជះឥទ្ធិពលមិនល្អទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ សកម្មភាពបំពុលបរិស្ថានរួមមានដូចជា ការបំពុលខ្យល់ ការបោះបង់សំណល់គ្រោះថ្នាក់នានា និងការទុកដាក់សំណល់រឹងរាវនានាដោយគ្មានការទទួលខុសត្រូវ។ ក្នុងន័យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានក្នុងសហគមន៍ និងបង្ការទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមានចំពោះបរិស្ថាននៅក្នុងការអនុវត្តគម្រោង រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- ការប្រើប្រាស់ទឹក ខ្យល់ ដី និងវត្ថុធាតុដើមសម្រាប់សំណង់ក្នុងការអនុវត្តគម្រោងក្នុងមូលដ្ឋានក្នុងបរិមាណសមស្របដែលមិនបង្កផលប៉ះពាល់ជាអវិជ្ជមានដល់សហគមន៍ ប្រកបដោយចីរភាព ប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់
- ប្រើប្រាស់ទឹកសម្រាប់ការអនុវត្តគម្រោងក្នុងបរិមាណសមស្រប ដែលមិនបង្កផលប៉ះពាល់ដល់គុណភាពទឹក និងនិរន្តរភាពនៃប្រភពទឹកប្រើប្រាស់របស់សហគមន៍
- ការប្រើប្រាស់វត្ថុធាតុដើមសម្រាប់សំណង់ (ដី គ្រួស ថ្ម ខ្សាច់ ជាដើម) ក្នុងបរិមាណមិនសមស្រប ដែលអាចបង្កផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន និងនិរន្តរភាពនៃការប្រើប្រាស់របស់សហគមន៍
- គ្មានការបំពុលបរិស្ថានដោយសារការអនុវត្តគម្រោងក្នុងសហគមន៍ ដោយត្រូវជៀសវាងរាល់សកម្មភាពនានាដែលបំពុលទៅលើខ្យល់ ទឹក និងដី បើសិនជាសកម្មភាពទាំងនោះមិនអាចជៀសផុតពីការបំពុលបរិស្ថានទេនោះ ត្រូវតែធ្វើផែនការកាត់បន្ថយការបំពុលទាំងនោះឱ្យនៅកម្រិតអប្បបរិមា
- ត្រូវជៀសវាងនូវការបង្កើនសំណល់នានា ទាំងសំណល់គ្រោះថ្នាក់ និងសំណល់មិនគ្រោះថ្នាក់ ប្រសិនបើមិនអាចជៀសវាងបាន គួរកាត់បន្ថយសំណល់ទាំងនោះឱ្យនូវកម្រិតទាបបំផុត
- សម្ភារទាំងឡាយណាដែលអាចបង្កឱ្យមានគ្រោះថ្នាក់ និងមិនមានសុវត្ថិភាពក្នុងការប្រើប្រាស់សម្រាប់កម្មករ ឬអ្នកអនុវត្តគម្រោង ត្រូវតែជំនួសវិញដោយសម្ភារដែលមិនមានគ្រោះថ្នាក់ និងមានសុវត្ថិភាព និងត្រូវជៀសវាងនូវការផលិត ការដោះដូរ ការប្រើប្រាស់សារធាតុគីមីដែលច្បាប់បានហាមឃាត់

- គ្រប់គ្រងលើវិធានការចម្រុះគ្រប់គ្រងដំណាំ (អាយភីអឹម-IPM) ការពារដំណាំនានាដោយត្រូវធានាគ្រប់គ្រងលើការប្រើប្រាស់សារធាតុពុលក្នុងវិធានការនេះ និងមិនធ្វើឱ្យបំពុលដល់ជីវចម្រុះដែលមាននៅក្នុងតំបន់របស់សហគមន៍
- មានការទទួលការខុសត្រូវក្នុងការបំភាយឧស្ម័នផ្ទះកញ្ចក់ឱ្យមានតុល្យភាពក្នុងបរិស្ថាន
- ធ្វើការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងគម្រោងទាំងឡាយណា ដែលមានបំភាយឧស្ម័ននេះទៅក្នុងបរិយាកាស។

## យុទ្ធសាស្ត្រទី៤ ៖ សុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍

សកម្មភាពនៃការអនុវត្តគម្រោង ត្រូវបានទទួលស្គាល់ថា បានរួមចំណែកក្នុងការបង្កហានិភ័យ និងផលប៉ះពាល់នានាដល់សហគមន៍ តាមរយៈសម្ភារបរិក្ខាសំណង់ សារធាតុគីមីដែលប្រើប្រាស់ក្នុងបច្ចេកទេសសំណង់ និងហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង។ ដើម្បីកាត់បន្ថយផលប៉ះពាល់លើសុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍ឱ្យបានជាអតិបរមា រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធត្រូវគិតគូរឱ្យបានស៊ីជម្រៅមុនពេលអនុវត្តគម្រោងចាំបាច់ត្រូវកំណត់ និងវាយតម្លៃផលប៉ះពាល់ ឬហានិភ័យដែលអាចកើតមាននៅអំឡុងពេលសាងសង់ និងបញ្ចប់គម្រោង។ ភ្នាក់ងារអនុវត្តគម្រោងត្រូវអនុវត្តនូវគោលការណ៍ដូចខាងក្រោម៖

- វិភាគ និងបញ្ចៀសនូវរាល់ផលប៉ះពាល់ជាអវិជ្ជមានទៅលើសុខភាព និងសុវត្ថិភាព របស់ប្រជាពលរដ្ឋក្នុងអំឡុងពេលអនុវត្ត និងក្រោយពេលអនុវត្តគម្រោង
- បញ្ចៀស ឬកាត់បន្ថយកត្តានានា ដែលនាំឱ្យសហគមន៍ប្រឈមទៅនឹងជម្ងឺផ្សេងៗដែលមានផលប៉ះពាល់ទៅលើសុខភាពរបស់ប្រជាពលរដ្ឋ ដោយរួមបញ្ចូលទាំងជម្ងឺដែលបង្កឡើងដោយសំណល់គ្រោះថ្នាក់នានា ជម្ងឺឆ្លងតាមទឹក និងប្រព័ន្ធដង្កើមជាដើម
- គ្រប់គ្រង និងរៀបចំសុវត្ថិភាពសារធាតុបង្កគ្រោះថ្នាក់ ដែលបង្កការប្រឈមដល់សហគមន៍ ក៏ដូចជាគំរាមកំហែងដល់សុខភាព ឬអាយុជីវិតប្រជាពលរដ្ឋ និងកម្មករ
- រៀបចំវិធានការត្រៀមបង្ការចំពោះស្ថានភាពអាសន្នក្នុងកំឡុងពេលអនុវត្តគម្រោង នៅពេលដែលមានឧបទ្ទវហេតុ និងគ្រោះថ្នាក់ដែលបណ្តាលមកពីការធ្វេសប្រហែសក្នុងការអនុវត្តគម្រោងមកពីគ្រោះធម្មជាតិ អគ្គីភ័យ ការផ្ទុះ ឬការលេចធ្លាយនូវសារធាតុគីមីជាដើម
- វិភាគ និងកាត់បន្ថយហានិភ័យនានា ដែលអាចប៉ះពាល់ទៅលើសុវត្ថិភាពរបស់សហគមន៍ក្នុងអំឡុងពេលអនុវត្តគម្រោង និងក្រោយពេលបញ្ចប់គម្រោង ដែលអាចបង្កឡើងដោយសម្ភារបរិក្ខាសំណង់ ឬប្លង់បច្ចេកទេសនៃសំណង់ ជាពិសេសផលប៉ះពាល់ទៅលើក្រុមជនងាយរងគ្រោះ ដូចជាស្ត្រី កុមារ ចាស់ជរា ជនពិការជាដើម
- ការពារសិទ្ធិសេរីភាពរបស់សហគមន៍ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់សកម្មភាពល្មើសនានា កំណត់មុខសញ្ញាល្មើស និងចាត់វិធានការសមស្របតាមគោលការណ៍នៃច្បាប់
- វិភាគ និងបញ្ចៀសឱ្យបានជាអតិបរិមានូវផលប៉ះពាល់ទៅលើប្រព័ន្ធអេកូឡូស៊ីដូចជាបាត់បង់តំបន់ទ្រនាប់នៃតំបន់ការពារ មានព្រៃកោងកាង ព្រៃឈើ ព្រៃលិចទឹក ឬធនធានទឹកសាបដែលជាទីអាស្រ័យផលរបស់សហគមន៍។

## យុទ្ធសាស្ត្រទី៥ ៖ លទ្ធកម្មដីធ្លី និងតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត

ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធត្រូវបានទទួលស្គាល់ថា មានការពាក់ព័ន្ធទៅនឹងលទ្ធកម្មដីធ្លី ប៉ះពាល់ដល់ដីកម្មសិទ្ធិ ដីសហគមន៍ ដីលំនៅដ្ឋាន និងដីអាស្រ័យផលរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ហើយអាចបង្កផលប៉ះពាល់ជាអវិជ្ជមានលើប្រភពចំណូល ឬប្រភពប្រកបរបរចិញ្ចឹមជីវិតផ្សេងៗទៀត។ ការប៉ះពាល់លើដីលំនៅដ្ឋាន អាចឈានដល់ការបាត់បង់ទីលំនៅរបស់សហគមន៍ផងដែរ។ សុវត្ថិភាពដីធ្លីត្រូវបានធានាតាំងពីដំណាក់កាលដំបូងនៃការសិក្សាគម្រោង ដែលទាមទារឱ្យមានការទទួលខុសត្រូវខ្ពស់ក្នុងការសិក្សា ពិចារណាទៅលើលទ្ធកម្មដីធ្លី និងការតាំងទីលំនៅដោយមិនស្ម័គ្រចិត្តប្រកបដោយតម្លាភាព និងមានគណនេយ្យភាព។ ការអនុវត្តគម្រោងត្រូវប្រាកដថាមិនមានបង្កផលប៉ះពាល់ជាអវិជ្ជមានទៅលើដីធ្លី និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ។ ដើម្បីបញ្ចៀសឱ្យបាននូវផលប៉ះពាល់អវិជ្ជមានទាំងនេះជាអតិបរិមា រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖

- ជៀសវាងឱ្យបាននូវរាល់ការបណ្តេញចេញដោយបង្ខំ ការគំរាមកំហែង និងការផ្លាស់ទីលំនៅរបស់សហគមន៍
- ជៀសវាងឱ្យបាន នូវរាល់ការតាំងទីលំនៅរបស់សហគមន៍ដោយមិនមានការស្ម័គ្រចិត្ត
- សិក្សា ពិចារណា ដោយប្រាកដប្រជាជាមួយប្រជាពលរដ្ឋលើលទ្ធកម្មដីធ្លី មានការបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត និងការទូទាត់សំណង
- ទូទាត់សំណងដល់ជនដែលត្រូវបានផ្លាស់ទីលំនៅដល់ជនដែលមានកម្មសិទ្ធិស្របច្បាប់ដោយសារការអនុវត្តគម្រោង ដោយស្មើភាពគ្នា និងទទួលបានសំណងស្មើនឹងតម្លៃសេដ្ឋកិច្ចដែលត្រូវបានបាត់បង់ដូចជា ដីធ្លី ទ្រព្យសម្បត្តិផ្សេងៗ ចំណូល និងស្តារឡើងវិញនូវបរិស្ថានក្នុងការរស់នៅ និងសុខុមាលភាពដែលបាត់បង់
- ធ្វើឱ្យប្រសើរឡើងវិញនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងនោះ ដែលត្រូវបានផ្លាស់ទីលំនៅដោយសារតែការអនុវត្តគម្រោង
- ធានាឱ្យមានការផ្តល់នូវសិទ្ធិកាន់កាប់ដីធ្លីដល់ជនដែលត្រូវបានផ្លាស់ទីលំនៅដោយស្របច្បាប់តាមរយៈការចេញប័ណ្ណកម្មសិទ្ធិជូន ឬសំណងជាសាច់ប្រាក់សម្រាប់ការរៀបចំប័ណ្ណកម្មសិទ្ធិ
- ធានាផ្តល់ជូនទីលំនៅ និងទ្រព្យសម្បត្តិដែលបាត់បង់ដល់ជនដែលគ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់ដែលត្រូវបានផ្លាស់ទីលំនៅដោយសារការអនុវត្តគម្រោង។

## យុទ្ធសាស្ត្រទី៦ ៖ ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិត ប្រកបដោយចីរភាព

ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិដែលមានជីវិតប្រកបដោយចីរភាព ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដែលទាមទារឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ យកចិត្តទុកដាក់ខ្ពស់លើផលប្រយោជន៍ដែលទទួលបានពីការអភិវឌ្ឍគម្រោង ដោយប្រៀបធៀបនិងតម្លៃសេដ្ឋកិច្ចនៃគុណប្រយោជន៍របស់ជីវចម្រុះ និងធនធានធម្មជាតិមានជីវិត។ រាល់ការអនុវត្តគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសិក្សា និងលើកវិធានការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានឱ្យបានជាអតិបរិមាលើជីវចម្រុះ ប្រព័ន្ធអេកូឡូស៊ី ប្រភេទសត្វកម្រ

និងធនធានមានជីវិត។ ដូច្នេះ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- វាយតម្លៃ ឬកាត់បន្ថយនូវផលប៉ះពាល់ ដោយវិភាគ និងបញ្ចៀសឱ្យបានរាល់ផលប៉ះពាល់ជាអវិជ្ជមានទៅលើជីវចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី បើសិនជាមិនអាចជៀសបានទេត្រូវអនុវត្តន៍វិធានការនានា ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមានឱ្យបានជាអតិបរិមា និងធ្វើឱ្យប្រសើរឡើងវិញនូវធនធានជីវចម្រុះ និងធនធានធម្មជាតិដែលមានជីវិតនៅក្នុងតំបន់ស្របទៅតាមច្បាប់
- លើកឡើងនូវវិធានការនានា ដើម្បីអភិរក្សតំបន់ជីវចម្រុះ ទោះបីជាមានការតាំងទីលំនៅ ឬការទន្ទ្រានដោយសកម្មភាពមនុស្សក្នុងតំបន់ការពារ ឬអភិរក្ស
- វិភាគលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ដោយសារតែការអនុវត្តគម្រោង និងបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាំងនោះជាអតិបរមា ឬធ្វើឱ្យនៅកម្រិតទាបបំផុតទៅលើប្រភេទកម្រ មានដូចជារុក្ខជាតិ និងសត្វដែលនៅក្នុងតំបន់អភិវឌ្ឍន៍នោះ
- មិនមានធ្វើការបម្លែង ឬធ្វើឱ្យផ្លាស់ប្តូរដែនជម្រកធម្មជាតិដែលមានស្រាប់ក្នុងតំបន់របស់សហគមន៍ឡើយ ដរាបណាមិនមានជម្រើសដ៏សមគួរណាមួយនោះទេ ត្រូវពិភាក្សាជាមួយអ្នកពាក់ព័ន្ធ និងត្រូវមានយន្តការកាត់បន្ថយនូវផលប៉ះពាល់លើការបាត់បង់ជីវចម្រុះនោះដោយជាក់លាក់បំផុត
- ជៀសវាងដាច់ខាតការអនុវត្តគម្រោងនៅទីជម្រកសំខាន់ៗ ប្រសិនបើមិនមានជម្រើសប្រសើរណាមួយនោះទេ ការអនុវត្តគម្រោងត្រូវធានាមិនមានផលប៉ះពាល់ជាអវិជ្ជមានទៅលើជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងទីជម្រកទាំងនោះឡើយ ហើយមិនបង្កឱ្យមានគ្រោះថ្នាក់ដល់ប្រភេទសត្វ និងរុក្ខជាតិដែលងាយរងគ្រោះ ព្រមទាំងធានាឱ្យមានប្រព័ន្ធតាមដានមួយអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព
- គម្រោងមិនអាចអនុវត្តក្នុងតំបន់ការពារបានទេ លើកលែងតែសកម្មភាពនោះត្រូវបានអនុញ្ញាតដោយច្បាប់ និងធានាថាអ្នកពាក់ព័ន្ធទាំងអស់បានចូលរួមក្នុងការអនុវត្តបានពេញលេញតាមច្បាប់នោះ និងបានខិតខំប្រឹងប្រែងខ្ពស់ក្នុងការរក្សានិងធ្វើឱ្យប្រសើរឡើងនៅក្នុងតំបន់អភិរក្សនោះ
- ធានាថាសកម្មភាពដែលចូលរួមចំណែកក្នុងផលិតផលធនធានធម្មជាតិមានជីវិត (ព្រៃឈើ កសិកម្ម សត្វ និងរុក្ខជាតិ) ត្រូវអនុវត្តស្របតាមស្តង់ដារជាតិ និងអន្តរជាតិស្តីពីការគ្រប់គ្រងដោយចីរភាព
- នៅក្នុងខ្សែសង្វាក់ផលិតកម្មលើធនធានជីវចម្រុះ និងធនធានធម្មជាតិដែលមានជីវិតត្រូវធ្វើការត្រួតពិនិត្យ និងតាមដានជាប្រចាំដោយភ្នាក់ងារអនុវត្តការងារនេះ ដើម្បីធានាថាធនធានធម្មជាតិ និងតំបន់អភិរក្សមិនត្រូវបានបំពាននិងធ្វើឱ្យរេចរិលឡើយ។

## យុទ្ធសាស្ត្រទី៧ ៖ ជនជាតិដើមភាគតិច

ក្រុមជនជាតិដើមភាគតិចដែលត្រូវបានស្គាល់ថាជាខ្មែរលើ មានប្រពៃណីវប្បធម៌ ទំនៀមទម្លាប់ ការប្រកបរបរចិញ្ចឹមជីវិតមានលក្ខណៈពិសេសខុសប្លែកពីខ្មែរក្រោមដែលរស់នៅរាយប៉ាយជាក្រុមតូចៗ។ ហើយក៏ត្រូវបានកំណត់ថាជាក្រុមងាយទទួលរងគ្រោះ ដែលត្រូវទទួលបានការយកចិត្តទុកដាក់ជាពិសេស និងធានាថារាល់ការអនុវត្តគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមិនមានផលប៉ះពាល់ជាអវិជ្ជមានណាមួយដល់ជីវភាពរស់នៅ ប្រពៃណី ទំនៀមទម្លាប់របស់ជនជាតិដើមភាគតិចឡើយ។ ការអនុវត្តគម្រោងនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានកិច្ចសហការគ្នាយ៉ាងជិតស្និតជាមួយតំណាងជនជាតិដើមភាគតិច និងត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋសហគមន៍ជនជាតិដើមភាគតិចលើគម្រោងអភិវឌ្ឍក្នុងមូលដ្ឋាន ហើយត្រូវអនុវត្តតាមគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- កំណត់ឱ្យបាននូវអត្តសញ្ញាណនៃជនជាតិដើមភាគតិច ធនធានធម្មជាតិ និងតំបន់រស់នៅរបស់ពួកគាត់ដែលរងទទួលនូវផលប៉ះពាល់ដោយសារគម្រោង និងធានាបានថា គម្រោងនឹងផ្តល់ផលប្រយោជន៍ដល់ជនជាតិដើមភាគតិច
- ជៀសវាងឱ្យបាននូវផលប៉ះពាល់ជាវិជ្ជមានទៅលើវប្បធម៌របស់ជនជាតិដើមភាគតិច បើសិនជាមិនអាចជៀសវាងបាន ត្រូវធានាកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានទាំងនោះជាអតិបរមា និងត្រូវស្តារឡើងវិញ ឬប៉ះប៉ូវទៅលើសកម្មភាពនានាដែលប៉ះពាល់ដល់វប្បធម៌របស់ពួកគាត់
- ជៀសវាងឱ្យបាននូវការអនុវត្តគម្រោង ដែលមានផលប៉ះពាល់ទៅលើទីសក្ការបូជា ឬដីប្រើប្រាស់របស់ជនជាតិដើមភាគតិច លើកលែងតែគម្រោងនោះបានសិក្សាស៊ីជម្រៅពីផលប៉ះពាល់ទាំងនោះ ហើយបានជូនដំណឹងអំពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងត្រូវធានាថាជនជាតិដើមភាគតិចអាចអាស្រ័យផល ទទួលបានសំណង និងទទួលបានផលប្រយោជន៍សមស្របពីគម្រោងនោះ
- មិនអាចផ្លាស់ទីលំនៅរបស់ជនជាតិដើមភាគតិចពីទីតាំងចាស់របស់ពួកគាត់ ឬប្តូរធនធានធម្មជាតិដែលពួកគាត់អាស្រ័យផលឡើយ លើកលែងតែពួកគាត់បានយល់ព្រមដោយស្ម័គ្រចិត្ត
- ការអនុវត្តគម្រោងមិនត្រូវធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរទៅលើបេតិកភណ្ឌវប្បធម៌របស់ជនជាតិដើមភាគតិចឡើយ លើកលែងតែពួកគាត់យល់ព្រមផ្លាស់ប្តូរទីតាំងដោយស្ម័គ្រចិត្ត
- ជៀសវាងការប្រើប្រាស់វប្បធម៌ប្រពៃណីរបស់ជនជាតិដើមភាគតិច ក្នុងការធ្វើអាជីវកម្មនានា លើកលែងតែមានការឯកភាព និងទទួលបានអត្ថប្រយោជន៍សមស្របសម្រាប់លើកកម្ពស់ជីវភាពរស់នៅរបស់ពួកគាត់
- រាល់ការរៀបចំអនុវត្តសកម្មភាពនានារបស់គម្រោង ត្រូវតែមានការចូលរួម និងពិភាក្សាជាមុនជាមួយជនជាតិដើមភាគតិច ពិសេសតំណាង និងមេភូមិរបស់ពួកគាត់។

## យុទ្ធសាស្ត្រទី៨ ៖ បេតិកភណ្ឌវប្បធម៌

ប្រទេសកម្ពុជាជាប្រទេសសម្បូរទៅដោយបេតិកភណ្ឌវប្បធម៌រូបី និងអរូបី ដែលមានតួនាទីដ៏សំខាន់ក្នុងសង្គមជាតិក្នុងការផ្សារភ្ជាប់នូវទំនាក់ទំនងរវាងមនុស្ស និងសង្គម ដែលជំនឿ ទំនៀមទម្លាប់ និងវប្បធម៌ទាំងនោះរួមចំណែកក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ និងភាពសុខដុមរបស់ប្រជាពលរដ្ឋ។ ក្នុងន័យនេះទាមទារឱ្យ

រដ្ឋបាលថ្នាក់ក្រោមជាតិជំរុញគាំទ្រលើកទឹកចិត្តដល់ការផលិត ការប្រើប្រាស់ផលិតផល ការផ្តល់សេវាកម្មវប្បធម៌ និងការចូលរួមសហការពីបណ្តាអង្គភាព និងស្ថាប័នពាក់ព័ន្ធ។ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោមដូចខាងក្រោម៖

- កំណត់ និងជៀសវាងនូវផលប៉ះពាល់វិជ្ជមានទៅលើបេតិកភណ្ឌវប្បធម៌រូបី (ទីតាំងបុរាណវិទ្យា ទីតាំងប្រវត្តិសាស្ត្រ) និងបេតិកភណ្ឌវប្បធ៌មអរូបី (ទីតាំងជំនឿ និងទីសក្ការបូជា)ជាដើម
- អនុវត្តនូវច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ ដើម្បីធានាបាននូវការអភិរក្ស និងមិនបង្កនូវផលប៉ះពាល់ជាអវិជ្ជមានដោយផ្ទាល់ និងដោយប្រយោលពីការអនុវត្តគម្រោង
- ពិគ្រោះយោបល់ជាមួយអាជ្ញាធរពាក់ព័ន្ធ ដូចជាអាជ្ញាធរអប្សរា អាជ្ញាធរព្រះវិហារ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់និងថ្លឹងថ្លែងឱ្យបានស៊ីជម្រៅនូវសារប្រយោជន៍នៃបេតិកភណ្ឌវប្បធម៌ ដោយធៀបទៅនឹងផលប្រយោជន៍ដែលទទួលបានពីគម្រោង
- បង្កើតឱ្យមានប្រព័ន្ធការពារបេតិកភណ្ឌវប្បធម៌ ដែលត្រូវបានប្រទះឃើញក្នុងអំឡុងពេលអនុវត្តគម្រោង
- ធានាថាប្រជាពលរដ្ឋក្នុងសហគមន៍អាចចូលរួមការពារទីតាំងបេតិកភណ្ឌវប្បធម៌ ដែលស្ថិតនៅក្នុងទីតាំងអនុវត្តគម្រោង
- ហាមឃាត់ដាច់ខាតនូវរាល់ការធ្វើឱ្យខូចខាត ឬធ្វើឱ្យបាត់បង់បេតិកភណ្ឌវប្បធម៌ លើកលែងតែក្នុងករណីដែលត្រូវបានអនុញ្ញាតដោយច្បាប់
- រាល់ការប្រើប្រាស់នូវបេតិកភណ្ឌអរូបីសម្រាប់ធ្វើការផ្សព្វផ្សាយ ត្រូវមានកិច្ចសហការជាមួយសហគមន៍ដែលពាក់ព័ន្ធ។

## VIII. ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យសម្រេចបានជោគជ័យដូចការរំពឹងទុក ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព គ.ជ.អ.ប. ត្រូវរៀបចំឱ្យមានប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដូចខាងក្រោម៖

### ១. យន្តការ

គ.ជ.អ.ប. ទទួលខុសត្រូវលើការតាមដាន ត្រួតពិនិត្យ វាយតម្លៃ សម្របសម្រួល និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើការអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ លេខាធិការដ្ឋាន គ.ជ.អ.ប. សហការជាមួយក្រសួងមហាផ្ទៃ ជាសេនាធិការឱ្យ គ.ជ.អ.ប. រៀបចំផែនការសកម្មភាពតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងធ្វើការតាមដានអនុវត្តជាប្រចាំ ព្រមទាំងរាយការណ៍ជូន គ.ជ.អ.ប. លើការអនុវត្តគោលនយោបាយនេះ។ ដើម្បីពិនិត្យមើលនូវប្រសិទ្ធភាពអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម សម្រាប់ដំណើរការតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រាប់រយៈពេលវែង គ.ជ.អ.ប. អាចធ្វើការវាយតម្លៃដោយក្រុមវាយតម្លៃឯករាជ្យ អាស្រ័យលើលទ្ធភាពធនធាន និងថវិកា។

### ២. ការដឹកនាំ និងសម្របសម្រួល

លេខាធិការដ្ឋាន គ.ជ.អ.ប. ដឹកនាំនិងសម្របសម្រួលការងារបច្ចេកទេស និងក្រសួង ស្ថាប័នពាក់ព័ន្ធ ពិនិត្យលើបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ សេចក្តីណែនាំ និងកំណត់នូវសកម្មភាពជាក់លាក់ ក្នុងការផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម សម្រាប់ដំណើរការតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

### ៣. ការគាំទ្រហិរញ្ញវត្ថុ

គ.ជ.អ.ប. កៀរគរថវិកាជាតិ និងថវិកាពីប្រភពផ្សេងៗទៀត ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមក្នុងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## VII. ផែនការសកម្មភាព

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គម ផែនការសកម្មភាពដែលត្រូវអនុវត្តជាចាំបាច់ រួមមាន៖

- លេខាធិការដ្ឋាន គ.ជ.អ.ប. រៀបចំផ្សព្វផ្សាយគោលនយោបាយនេះដល់ក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់បានជ្រាប និងអនុវត្តន៍
- ពិនិត្យ និងកែសម្រួលគោលការណ៍ណែនាំស្តីពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដែលមានចែងនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត
- សិក្សា និងធ្វើបច្ចុប្បន្នភាពលើសេចក្តីណែនាំស្តីពីការបង្កើតយន្តការផ្សេងៗ សម្រាប់អនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម
- អភិវឌ្ឍន៍សមត្ថភាពអំពីការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម ដល់មន្ត្រីពាក់ព័ន្ធក្នុងការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំសេចក្តីណែនាំស្តីពីការផ្តល់ព័ត៌មានត្រលប់ និងការរៀបចំរបាយការណ៍ ស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសង្គម
- រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវរៀបចំសកម្មភាពរបស់ខ្លួនតាមបទបញ្ញត្តិនានាដែលបានកែសម្រួលនេះ
- លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងបង្កើតគោលការណ៍ណែនាំសម្រាប់សិក្សាហានិភ័យលើបរិស្ថាន និងសង្គមក្នុងការអនុវត្តគម្រោងស្របទៅតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ គោលការណ៍នេះនឹងអនុវត្តនៅគម្រោងវិនិយោគថ្មីៗដែលគាំទ្រថវិកាវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬគម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានទឹកប្រាក់វិនិយោគច្រើនជាងមួយកោដិរៀល។ គោលការណ៍ណែនាំនេះមិនអនុវត្តន៍ចំពោះគម្រោងទាំងឡាយណាដែលបានធ្វើការវិភាគផលប៉ះពាល់បរិស្ថាន និងសង្គមដោយស្ថាប័នជំនាញរបស់ដៃគូអភិវឌ្ឍន៍ ឬក៏បានអនុវត្តស្របទៅតាមឯកសារណែនាំរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។ គោលការណ៍ណែនាំនេះ មាន

ភ្ជាប់នៅក្នុងឧបសម្ព័ន្ធ២ ដែលគោលការណ៍នេះនឹងធ្វើបច្ចុប្បន្នភាព និងសម្រេចដោយដោយប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.

- គម្រោងទាំងឡាយណាដែលអនុវត្តក្នុងក្របខណ្ឌកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវធ្វើចំណាត់ថ្នាក់ហានិភ័យ។ គម្រោងទាំងឡាយណាដែលមានហានិភ័យខ្ពស់នឹងត្រូវចាត់ចូលក្នុង (ចំណាត់ថ្នាក់A) គម្រោងដែលមានហានិភ័យមធ្យមនឹងត្រូវចាត់ចូលក្នុង (ចំណាត់ថ្នាក់B) និងគម្រោងដែលមានហានិភ័យទាបនឹងត្រូវចាត់ចូលក្នុង (ចំណាត់ថ្នាក់C)។ គម្រោងដែលមានហានិភ័យខ្ពស់ក្នុង (ចំណាត់ថ្នាក់A) គឺជាគម្រោងទាំងឡាយណាដែលតម្រូវការសិក្សាជាក់លាក់បន្ថែមទៀត ដូចជាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។ ចំពោះគម្រោងដែលមានហានិភ័យមធ្យម (ចំណាត់ថ្នាក់B) គឺជាគម្រោងទាំងឡាយណាដែលតម្រូវឲ្យមានការធ្វើផែនការគ្រប់គ្រងបរិស្ថាន និងសង្គម
- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តល់ដំណឹងដល់លេខាធិការដ្ឋាន គ.ជ.អ.ប. ជាប្រចាំលើការអនុវត្តគម្រោងវិនិយោគទាំងឡាយណាដែលមានបង្កហានិភ័យលើលើបរិស្ថាន និងសង្គម ។ លេខាធិការដ្ឋាន គ.ជ.អ.ប. ធ្វើតាមដានការគ្រប់គ្រងហានិភ័យលើបរិស្ថាន និងសង្គម ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់ថារដ្ឋបាលថ្នាក់ក្រោមជាតិបានអនុវត្តទៅតាមគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គម
- លេខាធិការដ្ឋាន គ.ជ.អ.ប. ចាត់បញ្ជូនមន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ធ្វើការត្រួតពិនិត្យការអនុវត្តគោលនយោបាយសុវត្ថិភាពនេះ។ មន្ត្រីទាំងនេះនឹងត្រូវបង្កើតឡើងដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងមិននៅក្រោមការគ្រប់គ្រងរបស់ផ្នែកអនុវត្តគម្រោងណាមួយឡើយ។ មន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គមនឹងត្រូវ ១. ពិនិត្យគម្រោងទាំងអស់ និងធ្វើការចាត់ថ្នាក់ប្រភេទនៃហានិភ័យលើបរិស្ថាន និងសង្គម ២. ជួយដល់ក្រុមអនុវត្តគម្រោង និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (សម្រាប់គម្រោងដែលមានទឹកប្រាក់លើសពី១កោដិរៀល) ៣. ត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងសង្គម និង ៤. ផ្សព្វផ្សាយព័ត៌មាន បង្កើនការយល់ដឹង និងអភិវឌ្ឍន៍សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តន៍គោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គម។ លក្ខខណ្ឌការងាររបស់មន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គមមាននៅក្នុងឧបសម្ព័ន្ធទី៣ និងអាចមានធ្វើបច្ចុប្បន្នភាពដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ។

## VIII. ឥស្សុតាខ និខយន្តការដោះស្រាយពាក្យបណ្តឹខ

ប្រជាពលរដ្ឋដែលរនូវផលប៉ះពាល់ជាអវិជ្ជមាន ដោយហានិភ័យលើបរិស្ថាន និងសង្គម មានសិទ្ធិគ្រប់គ្រាន់ក្នុងការចូលរួមផ្តល់ព័ត៌មានអំពីវិធានការគ្រប់គ្រងហានិភ័យ។ ប្រជាពលរដ្ឋមានសិទ្ធិលើការពិគ្រោះផ្តល់យោបល់ និងផ្តល់យោបល់លើសំណើគម្រោង។ ប្រជាពលរដ្ឋដែលទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមានដោយសារហានិភ័យបរិស្ថាន និងសង្គមរបស់គម្រោងណាមួយ ឬប្រាកដថាគោលនយោបាយសុវត្ថិភាពបរិស្ថាន និងសង្គមមិនបានអនុវត្តត្រឹមត្រូវមានសិទ្ធប្តឹងតវ៉ា។

សម្រាប់គម្រោងណាដែលនៅក្រោមការគ្រប់គ្រងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបានដាក់បង្ហាញលទ្ធផលនៃការត្រួតពិនិត្យសុវត្ថិភាពបរិស្ថាន និងសង្គម ព្រមទាំងផែនការគ្រប់គ្រងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៅក្នុងវេបសាយរបស់ គ.ជ.អ.ប.។

គោលការណ៍អនុវត្តគម្រោងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវដាក់បង្ហាញឲ្យឃើញអំពីហានិភ័យបរិស្ថាននិងសង្គម។

ប្រជាពលរដ្ឋដែលរងនូវផលប៉ះពាល់ដោយសារគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិក្នុងការដាក់ពាក្យបណ្តឹងតវ៉ាដោយផ្ទាល់ទៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការិយាល័យប្រជាពលរដ្ឋ។

ប្រជាពលរដ្ឋមានសិទ្ធិដាក់បណ្តឹងតវ៉ាបានដោយផ្ទាល់ទៅលេខាធិការដ្ឋាន គ.ជ.អ.ប. ជាលាយលក្ខណ៍អក្សរតាមរយៈសារអេឡិចត្រូនិករបស់ គ.ជ.អ.ប. ឬតាមរយៈទូរស័ព្ទ ឬតាមរយៈបុគ្គលទទួលបន្ទុក។ លេខាធិការដ្ឋាន គ.ជ.អ.ប. រក្សាទុកពាក្យបណ្តឹងទាំងនោះជាឯកសារ និងធ្វើការអង្កេតទៅតាមរាល់ពាក្យបណ្តឹងតាមគោលនយោបាយ និងគោលការណ៍នានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។

## IX. សេចក្តីសន្និដ្ឋាន

គោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ដំណើរការតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងយន្តការសុវត្ថិភាពបរិស្ថាន និងសង្គមនៅក្នុងការអនុវត្តគម្រោងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមលំដាប់ថ្នាក់នីមួយៗ ប្រកដោយស្វ័យភាព ការទទួលខុសត្រូវគណនេយ្យភាព និងតម្លាភាព ស្របទៅនឹងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។ គោលនយោបាយនេះនឹងត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅក្នុងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងគម្រោងមូលនិធិឃុំ សង្កាត់គម្រោងក្រុង ស្រុក ខណ្ឌ និងគម្រោងរាជធានី ខេត្ត ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

គោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាន និងសង្គមសម្រាប់ដំណើរការតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានបង្ហាញនូវឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និងកិច្ចអភិវឌ្ឍមូលដ្ឋាន ដោយបញ្ចៀសបាននូវផលប៉ះពាល់ និងហានិភ័យជាអតិបរិមា ទៅលើបរិស្ថាន ធនធានធម្មជាតិ ធានាបាននូវសុវត្ថិភាពដីធ្លី ការពារសុវត្ថិភាពជនជាតិដើមភាគតិច លើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន សមធម៌សង្គម ប្រពៃណី វប្បធម៌ ប្រកបដោយចីរភាព និងភាពសុខដុមក្នុងប្រទេសកម្ពុជា៕

# សន្ទានុក្រម

**គ.ជ.អ.ប.** គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅលើរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដែលរដ្ឋបាលនីមួយៗមានក្រុមប្រឹក្សាមួយជាតំណាង។

**វិមជ្ឈការ** មានន័យថា រាជរដ្ឋាភិបាល ប្រគល់នូវភាពជាម្ចាស់ លើមុខងារ សិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ឲ្យទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ដូចជា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន។

**វិសហមជ្ឈការ** មានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន ធ្វើប្រតិភូកម្ម មុខងារ សិទ្ធិអំណាច និងធនធាន(ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិក) ទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនោះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ននោះ។ ក្នុងន័យនេះ ភាពជាម្ចាស់មិនផ្តល់ជូនអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល បានរក្សាទុកនូវភាពជាម្ចាស់នោះ។

**បទដ្ឋានអន្តរជាតិ** គឺជាលិខិតដែលកំណត់ដោយវិធាន ឬគោលការណ៍លំនាំច្បាប់ដែលគ្រប់ជាតិសាសន៍អនុវត្តតាម

**សង្គម** គឺជាការប្រមូលផ្តុំគ្នារស់នៅរវាងមនុស្ស ឬសត្វដោយមានច្បាប់ ប្រពៃណី ទំនៀមទម្លាប់ និងសាសនា។

**ការវាយតម្លៃ** ជាការវិនិច្ឆ័យលើគុណតម្លៃ ផលប្រយោជន៍ និងតម្លៃនៃការងារអ្វីមួយ ជាការសិក្សាវាយតម្លៃអំពីភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព ផលប៉ះពាល់ និរន្តរភាព និងភាពពាក់ព័ន្ធនៃគម្រោងមួយ ស្របតាមគោលបំណងនានាដែលបានកំណត់។

**ផលប៉ះពាល់** ការជះឥទ្ធិពលជាវិជ្ជមាន និងអវិជ្ជមានចំពោះមុខ និងយូរអង្វែង ដែលផ្តើមចេញពីកិច្ចអន្តរាគមន៍នៃការអភិវឌ្ឍមួយមានលក្ខណៈដោយផ្ទាល់ ឬដោយប្រយោលដោយចេតនា ឬដោយអចេតនា។

**សុវត្ថិភាព** គឺជាការដែលប្រកបដោយសេចក្តីសុខដោយការពារបាននូវហានិភ័យដែលអាចកើតឡើង។

**តម្លាភាព** ការផ្តល់នូវព័ត៌មានទាន់ពេលវេលា និងអាចជឿទុកចិត្តបាន ហើយព័ត៌មាននេះអាចទទួលបានការប្រើប្រាស់ដោយអ្នកពាក់ព័ន្ធទាំងអស់។

| | |
|---|---|
| **ជនជាតិដើមភាគតិច** | គឺសំដៅលើជនជាតិដើមជាម្ចាស់ស្រុកភាគច្រើនរស់នៅតំបន់ខ្ពង់រាបនៃប្រទេសកម្ពុជា។ |
| **យន្តការ** | គឺជាប្រព័ន្ធការងារមួយសម្រាប់ដំណើរការត្រួតពិនិត្យលើការងារមួយទៀត។ |
| **គោលនយោបាយ** | គឺជាចំណុចគោលដៅសំខាន់ដែលដឹកនាំអ្នកដទៃឱ្យទៅតាមគោលដៅនោះ។ |
| **ហានិភ័យ** | គឺជាមហន្តរាយដែលកើតមានឡើងនៅក្នុងធម្មជាតិប៉ះពាល់ទៅលើធម្មជាតិ និងជីវភាពរស់នៅរបស់មនុស្ស។ |
| **ពលកម្មកុមារ** | គឺជាការបញ្ចេញកម្លាំងកាយបម្រើការងារអ្វីមួយ ដែលសំដៅដល់ការងារដែលត្រូវបំពេញដោយកុមារ ឬក្មេងដែលមានអាយុតិចជាងអាយុបានកំណត់ ដែលមិនស្របតាមបទបញ្ញត្តស្តង់ដារឬកម្រិតអង្គការពលកម្មពិភពលោក ដែលពាក់ព័ន្ធនានា និងជាការងារទាំងឡាយណា ដែលមានលក្ខណៈគ្រោះថ្នាក់ ឬជ្រៀតជ្រែកដល់ការអប់រំរបស់កុមារ ឬក្មេង ឬការងារដែលបង្កគ្រោះថ្នាក់ដល់សុខភាពឬរាងកាយ ស្មារតីផ្លូវចិត្ត សីលធម៌ ឬការអភិវឌ្ឍសង្គមរបស់ក្មេង និងកុមារ ។ |
| **សុខដុមរមនា** | គឺការរស់នៅផ្តុំគ្នាឬនៅមូលគ្នាឥតមោះហ្មង ឬសេចក្តីរីករាយសប្បាយដោយការរស់នៅមូលគ្នាដោយសុខស្រួល ។ |
| **សុខុមាលភាព** | សំដៅភាពនៃបុគ្គលអ្នកមានសេចក្តីសុខដែលមិនជួបប្រទះការលំបាក។ |
| **ជីវចម្រុះ** | គឺសំដៅដល់សារពាង្គកាយនៅក្នុងប្រភេទតែមួយ ឬផ្សេងគ្នា និងបណ្តាសារពាង្គកាយនៃគ្រប់លំដាប់ថ្នាក់ និងប្រភពទាំងអស់ រួមទាំងប្រព័ន្ធអេកូឡូស៊ីដែនដីគោក ដែនសមុទ្រ ដែនទឹកសាប និងបណ្តាទំនាក់ទំនងអេកូឡូស៊ី ។ |
| **និរន្តរភាព** | គឺធ្វើឱ្យមានភាពស្ថិតស្ថេរ ឬមានចីរភាពដំណើរការអភិវឌ្ឍន៍អ្វីមួយដោយមិនមានហានិភ័យកើតឡើង។ |
| **ធនធានធម្មជាតិ** | គឺជាធនធានដែលមានស្រាប់នៅក្នុងធម្មជាតិ រួមមាន ព្រៃឈើ ផ្លូវទឹក រុក្ខជាតិ និងសត្វព្រៃ។ |
| **បេតិកភណ្ឌវប្បធម៌** | គឺជាទ្រព្យសម្បត្តិកេរ្តិ៍ដំណែលវប្បធម៌ជាតិដែលមានតាំងពីដូនតា សម្រាប់ជាមរតករួមរបស់ជាតិ។ |
| **ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន** | គឺជាហេដ្ឋារចនាសម្ព័ន្ធ បរិយាយអំពីទ្រព្យបង្កើតឡើង ដែលអនុញ្ញាតឱ្យប្រទេសមួយដំណើរការ ដូចជាផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ព្រលានយន្តហោះ ប្រព័ន្ធគមនាគមន៍ អគ្គិសនី និងបណ្តាញចែកចាយទឹកស្អាតនៅមូលដ្ឋាន។ |
| **ប្រសិទ្ធភាព** | ភាពដែលល្អផ្តល់ផលល្អផ្តល់ប្រយោជន៍សមបំណង។ |
| **ប្រសិទ្ធផល** | សំដៅដល់លទ្ធផលចុងក្រោយ ឬគុណភាពដែលមានឥទ្ធិពល ឬប៉ះពាល់រយៈពេលវែង។ |

**ឧស្ម័នផ្ទះកញ្ចក់** ឧស្ម័នដែលមាននៅក្នុងបរិយាកាសដែលកើតឡើងដោយធម្មជាតិ ឬដោយសកម្មភាពមនុស្ស ហើយបានស្រូបយក និងបញ្ចេញរស្មីតាមជំហានរលកដាក់លាក់ក្នុងជំហានរលកនៃកាំរស្មីកម្ដៅក្រហមអាំងហ្វ្រា ដែលភាយចេញពីផ្ទៃផែនដី បរិយាកាស និងពពក។ បាតុភូតទាំងនេះបង្កឱ្យមានផលផ្ទះកញ្ចក់។ ចំហាយទឹក($H_2O$) ឧស្ម័នកាបូនិច($CO_2$) ឌីអាសូតម៉ូណូអុកស៊ីត($N_2O$) មេតាន($CH_4$) និងអូហ្សូន($O_3$) ជាឧស្ម័នផ្ទះកញ្ចក់ចម្បងៗនីក្នុងបរិយាកាសរបស់ផែនដី។

**ជម្រកធម្មជាតិ** គឺជាតំបន់ដីគោក និងដែនទឹក ដែលជាបណ្ដុំជីវសាស្ត្រកើតឡើងពីប្រភេទសត្វ និងរុក្ខជាតិប្រចាំតំបន់ជាចម្បង និងជាតំបន់ដែលសកម្មភាពរបស់មនុស្សមិនបានកែប្រែជាសារវន្តទៅលើមុខងារអេកូឡូស៊ីចម្បងរបស់តំបន់នោះ។

**អភិវឌ្ឍន៍ដោយចីរភាព** សំដៅដល់ការអភិវឌ្ឍដែលនាំមកនូវការរីកចម្រើនសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាពបរិស្ថាន ដោយផ្អែកលើតុល្យភាពនៃបង្គោលគ្រឹះបួនគឺ សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌។

**សំណល់គ្រោះថ្នាក់** សំដៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជម្ងឺមហារីក និងជម្ងឺឆ្លង ធ្វើឱ្យរលាក ធ្វើឱ្យច្រេស ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀតដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញ ដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។

**បេតិកភណ្ឌវប្បធម៌** សំដៅដល់សម្បត្តិវប្បធម៌ទាំងរូបី និងអរូបី។

**គណនេយ្យភាពសង្គម** គឺជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយវាក៏ជាមធ្យោបាយមួយដែលបន្សីុគ្នារវាងគោលការណ៍ទាំងឡាយនៃអភិបាលកិច្ចដែលធ្វើសេចក្ដីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**អាយភីអឹម (IPM)** គឺអក្សរកាត់ជាភាសាឡាតាំងប្រើប្រាស់នៅក្នុងវិស័យកសិកម្មហៅថា វិធានការចម្រុះគ្រប់គ្រងដំណាំ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ ៖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលជាឯកសារយោង

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិ
- ច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីភូមិបាល
- ច្បាប់ស្តីពីព្រៃឈើ
- ច្បាប់ស្តីពីជលផល
- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី
- ច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលក្នុងអនុសញ្ញាជីវចម្រុះ
- ច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលក្នុងអនុសញ្ញាក្របខណ្ឌអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- ច្បាប់ស្តីពីការការពារពលកម្មកុមារ
- ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមលើពិធីសារក្យូតូ នៃអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច
- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង
- អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- អនុក្រឹត្យស្តីពីការបំពុលខ្យល់ និងការរំខានដោយសំលេង

**ឧបសម្ព័ន្ធ២៖** គោលគោលការណ៍សម្រាប់ការគ្រប់គ្រងហានិភ័យលើសុវត្ថិភាពបរិស្ថាន និងសង្គម សម្រាប់គម្រោងក្នុងក្របខណ្ឌនៃដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**ឧបសម្ព័ន្ធ៣៖** លក្ខខណ្ឌការងាររបស់មន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គមនៅលេខាធិការដ្ឋាន គ.ជ.អ.ប.